**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៤៥៨ ប្រក. កសក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើគំរូលិខិតអនុញ្ញាតនាំចូល នាំចេញសត្វព្រៃមានដោយបន្ទូរ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax : (855) 23 - 217 320

និងមាត្រា២៧ ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧

- បានឃើញប្រកាសលេខ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០០៧ ស្តីពីចំណាត់ថ្នាក់ និងការចុះបញ្ជីឈ្មោះប្រភេទសត្វព្រៃ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១._**

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើជាផ្លូវការនូវគំរូលិខិតអនុញ្ញាតនាំចូល នាំចេញសត្វព្រៃមានដោយបង្ករដូចមានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២._**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ធានាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់
- គ្រប់គ្រងការធ្វើចរាចរ ការធ្វើពាណិជ្ជកម្ម និងការនាំចូល នាំចេញសត្វព្រៃស្របតាមច្បាប់ស្តីពីព្រៃឈើនិងអនុសញ្ញាអន្តរជាតិ
- គាំទ្រការចូលរួមរបស់សហគមន៍មូលដ្ឋាន និងវិស័យឯកជនក្នុងការរួមចំណែកដល់ការគ្រប់គ្រងការពារ និងអភិរក្សធនធានសត្វព្រៃនិងប្រើប្រាស់ប្រកបដោយនិរន្តរភាព។

**ប្រការ ៣._**

ប្រកាសនេះមានវិសាលភាពអនុវត្តលើរាល់សកម្មភាពដែលពាក់ព័ន្ធនឹងសត្វព្រៃមានដោយបង្ករក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤._**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតនាំចូល នាំចេញសត្វព្រៃមានដោយបង្ករត្រូវដាក់ពាក្យស្នើសុំនៅរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦._**

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០កើត ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៥៤ ប្រក.កសក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើគំរូលិខិតអនុញ្ញាតនាំចូល នាំចេញសត្វព្រៃមានដោយបន្ទូរ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
រដ្ឋបាលព្រៃឈើ
FORESTRY ADMINISTRATION

លេខ : ..................................

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..............ឆ្នាំ២០........
Phnom Penh, ............................20.........

# លិខិតអនុញ្ញាតនាំចូល នាំចេញសត្វព្រៃមានដោយបន្ទូរ
## IMPORT EXPORT PERMIT FOR COMMON WILDLIFE SPECIES

1. យោង: Reference:

2. ☐ នាំចេញ EXPORT ☐ នាំចេញបន្ត RE-EXPORT ☐ នាំចូល IMPORT ☐ ផ្សេងៗ OTHER

3. មានសុពលភាពដល់ Valid Until

4. អ្នកនាំចូល "ឈ្មោះ និង អាសយដ្ឋាន" Importer (name and address)

4a. ប្រទេសនាំចូល Country of import

5. អ្នកនាំចេញ "ឈ្មោះ និង អាសយដ្ឋាន ប្រទេស" Exporter (name and address,country)

| | 6a. ឈ្មោះវិទ្យាសាស្ត្រ "ពួក និង ប្រភេទ" និងឈ្មោះសត្វព្រៃ Scientific name (Genus and Species) and Common name of Wildlife | 6b. រៀបរាប់អំពីសំណាកសត្វ Description of specimens | 6c.បរិមាណ "ជាឯកតា" Quantity (Including Unit) |
|---|---|---|---|
| 1 | | | |
| 2 | | | |
| 3 | | | |
| 4 | | | |
| 5 | | | |
| 6 | | | |

7. លិខិតអនុញ្ញាតនេះចេញដោយ THIS PERMIT IS ISSUED BY

រដ្ឋបាលព្រៃឈើ
FORESTRY ADMINISTRATION

អាសយដ្ឋានលេខ ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
N° 40 Preah Norodom Blvd, Sangkat Phsar Kandal 2, Khan Daun Penh, Phnom Penh, Cambodia

ទូរស័ព្ទ : (០២៣) ២១៤ ៦៥១/ ២១១ ៥៣៥/២១១ ៦៣៦
Phone: (023) 214 651 / 211 535 / 211 636